**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃសុក្រ ៥កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃសុក្រ ទី២៣ ខែមករា ឆ្នាំ២០២៦

**២. ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣៥រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣៩រូប សរុបចំនួន៧៤រូប។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ ពិនិត្យ និងពិភាក្សា នូវរបៀបវារៈ និងគោលបំណងនៃកិច្ចប្រជុំ ស្តីពីការជំរុញការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

៤.៣ ទិសដៅអនុវត្តក្នុងឆ្នាំ២០២៦។

៤.៤ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

ជាបឋម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវមតិស្វាគមន៍ដល់ក្រុមការងារ និងអង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមការងារ ក៏ដូចជាក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក។ ការសម្រេចបាននូវលទ្ធផលល្អប្រសើរកន្លងមកនេះ ដោយសារមានការយកចិត្តទុកដាក់គិតគូប្រកបដោយគតិបណ្ឌិតរបស់**សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដោយមានចូលរួមអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងផ្នែកជាតិ អន្តរជាតិ និងសង្គមស៊ីវិល ក្រោមការដឹកនាំប្រកប ដោយភាពឈ្លាសវៃ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការឈានទៅសម្រេចបានគោលនយោបាយជាតិទាំងបី៖

១- កាត់បន្ថយការចម្លងថ្មីតិចជាង ១នាក់ ឬប្រមាណជា ២០០នាក់ក្នុងមួយឆ្នាំ។
២- កាត់បន្ថយការស្លាប់ដោយសារមេរោគអេដស៍ឱ្យនៅក្រោម ២០០នាក់ក្នុងមួយឆ្នាំ។
៣- លុបបំបាត់ការមាក់ងាយ និងរើសអើង។

ឯកឧត្តមក៏បានជម្រាបជូនអង្គប្រជុំ ពីការរៀបចំនូវកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្តីពីការជំរុញការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដែលនឹងប្រព្រឹត្តនៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ នាថ្ងៃទី៣-៤ ខែកុម្ភៈ ឆ្នាំ២០២៦ ដែលនឹងកំណត់នូវសូចនាករសមិទ្ធកម្មសម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត អនុលោមទៅនឹងសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី។

ជាបន្ត **ឯកឧត្តមបណ្ឌិត** បានអនុញ្ញាត**លោកវេជ្ជ. ហួត សេរីវង្ស** ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បង្ហាញជូនអង្គប្រជុំពីរបៀបវារៈ និងគោលបំណងនៃកិច្ចប្រជុំស្តីពីការជំរុញការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍។ លោកបានជម្រាបជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំនោះនឹងអញ្ជើញឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ឱ្យចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធនិម្មិត។ លោកក៏បានជម្រាបអង្គប្រជុំពីវឌ្ឍនភាពស្ថានភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ថា ក្នុងឆ្នាំ២០២៤ កម្ពុជាមានអត្រាផ្ទុកមេរោគអេដស៍ចំនួន ០.៥ភាគរយ មានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ ៧៦ ០០០នាក់ និងមានអ្នកឆ្លងថ្មីប្រមាណជា ១ ២០០នាក់ ដែលក្នុងនោះប្រមាណជា ៨៨ភាគរយ ជាក្រុមប្រជាជនគន្លឹះ អតិថិជនរួមនឹងដៃគូ និងភាគច្រើនជាយុវវ័យ។ លោកក៏បានបង្ហាញនូវគោលបំណងកិច្ចប្រជុំមានដូចខាងក្រោម៖

- បង្កើនការយល់ដឹងរួមគ្នាលើការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។
- កំណត់នូវសូចនាករសម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្របតាមភារកិច្ចដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។
- បង្កើនការយល់ដឹងដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដើម្បីជំរុញការអនុវត្តលិខិតលេខ២១ សជណ កប ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ ស្តីពីករណីវិធានការជំរុញប្រសិទ្ធភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។
- ពង្រឹងភាពជាម្ចាស់ក្នុងការពង្រឹងប្រព័ន្ធជាតិឆ្លើយតបជាពហុវិស័យចំពោះមេរោគអេដស៍ និងជំងឺអេដស៍។
- លើកកម្ពស់ការយល់ដឹង និងប្រើប្រាស់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ក្នុងការងារឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍
- ធ្វើឱ្យកាន់តែប្រសើរឡើងនូវយន្តការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍រវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាបន្ត **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** បានអនុញ្ញាតឱ្យមានកិច្ចពិភាក្សាយ៉ាងផុលផុស និងផ្តល់ធាតុចូលដល់អង្គប្រជុំ៖

- កែសម្រួលសមាភាពបញ្ជីវត្តមានថ្មីសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស។
- តំណាងអ្នកផ្ទុកមេរោគអេដស៍សំណើរឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ជួយឧបត្ថម្ភសោហ៊ុយធ្វើដំណើរសម្រាប់អ្នកផ្ទុកមេរោគអេដស៍ទៅបើកថ្នាំនៅកន្លែងផ្តល់ថ្នាំប្រឆាំងមេរោកអេដស៍។

ទន្ទឹមនឹងនោះ **ឯកឧត្តមបណ្ឌិត** បានរំលឹកឡើងវិញនូវផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៣-២០២៨ ដែលមានចក្ខុវិស័យ៖ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញ គ្មានមេរោគអេដស៍ និងជំងឺអេដស៍ និងគ្មានការមាក់ងាយ រើសអើង និងមានបេសកកម្ម ធានាបាននូវការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍បានល្អ ដោយមានការចូលរួមប្រកបដោយបរិយាបន្នដោយមូលដ្ឋាន និងសហគមន៍ជាម្ចាស់ ផ្តោតលើប្រជាពលរដ្ឋជាធំ មានភាពធន និងមានចីរភាព ដោយមានគោលដៅ ការឆ្លើយតបនឹងមេរោគអេដស៍ជាពហុវិស័យប្រកបដោយចីរភាពដែលធានាថា ជំងឺអេដស៍លែងជាការគំរាមកំហែងសុខភាពសាធារណៈចាប់ពីឆ្នាំ២០២៨។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក និងបញ្ចប់នៅវេលាម៉ោង ១១:៣០នាទីថ្ងៃខែឆ្នាំដដែល ប្រកបដោយលទ្ធផលផ្លែផ្កា។ ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** បានជូនពរដល់សមាជិកអង្គប្រជុំ ឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ៩កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ

**បណ្ឌិត ឈឹម ឃិនដារ៉េត**

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

**វេជ្ជ. ហួត សេរីវុធ្ទ**

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**